**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជតក
**ដាក់ទៅ** : អង្គជំនុំជម្រះតុលាការកំពូល
**ថ្ងៃដាក់** : ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Mar-2021, 13:29
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា
## ស្តីពីកាលវិភាគសម្រាប់សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande NUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្តី**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្ដីផ្ដើម

១. នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) បានចេញកាលវិភាគបណ្ដោះអាសន្នមួយ[1] ដើម្បីបើកសវនាការស្ដាប់សារណារបស់គូភាគីជាម្ចាស់បណ្ដឹងសាទុក្ខ និងសហព្រះរាជអាជ្ញា[2] ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២[3]។ កាលវិភាគនេះកំណត់ប្រធានបទដែលត្រូវដោះស្រាយ និងពេលវេលាលែទុកសម្រាប់ភាគីនីមួយៗ សម្រាប់ប្រធានបទនីមួយៗ។ អ.ជ.ត.ក បានអញ្ជើញភាគីទាំងអស់ឱ្យដាក់សេចក្ដីសង្កេតរបស់ខ្លួនស្ដីពីកាលវិភាគនេះ។

២. សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធតែកាលវិភាគដែលបានស្នើសម្រាប់ម្ចាស់បណ្ដឹងសាទុក្ខ និងផ្អែកលើការប៉ាន់ប្រមាណនៃពេលវេលាដែលពួកគេត្រូវការ សម្រាប់ប្រធានបទនីមួយៗ មុនទទួលសំណួរជាក់លាក់របស់អង្គជំនុំជម្រះប៉ុណ្ណោះ។ និយាយដោយឡែក សហព្រះរាជអាជ្ញាសូមស្នើការបំភ្លឺលើប្រធានបទមួយ -គឺយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង - និងស្នើសុំពេលវេលាបន្ថែមសម្រាប់ធ្វើសារណាផ្ទាល់មាត់របស់ខ្លួន ទាក់ទងនឹងផ្នែកពីរផ្សេងទៀត គឺៈ ឧក្រិដ្ឋកម្មដែលម្ចាស់បណ្ដឹងសាទុក្ខត្រូវបានកាត់ឱ្យជាប់ទោស និងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ម្ចាស់បណ្ដឹងសាទុក្ខ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ពេលវេលាបន្ថែមនេះ គឺគួរទទួលបានការអនុញ្ញាតដោយសារមូលហេតុដូចខាងក្រោម។

## II. សេចក្ដីសង្កេត

### *យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង*

៣. ការបែងចែកពេលវេលាមានរយៈពេល ៥៥ នាទី សម្រាប់សហព្រះរាជអាជ្ញា គឺគ្រប់គ្រាន់សម្រាប់ប្រធានបទស្ដីពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។ យ៉ាងណាមិញ សហព្រះរាជអាជ្ញាស្នើ

---

[1] ឯកសារ **F60** ការអញ្ជើញដាក់សេចក្ដីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្ដឹងសារទុក្ខក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ (“ការអញ្ជើញឱ្យដាក់សេចក្ដីសង្កេតអំពីកាលវិភាគបណ្ដោះអាសន្ន”), KH 01664412។ ឯកសារ **F60.1** ឧបសម្ព័ន្ធ – កាលវិភាគសម្រាប់សវនាការ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ (“កាលវិភាគបណ្ដោះអាសន្ន”)។

[2] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន (០០២/០២) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ (“សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន”)។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក – សេចក្ដីសង្ខេបនៃទឡ្ហីករណ៍សម្រាប់បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២)។ ឯកសារ **F50** បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩។

[3] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

សុំការបំភ្លឺលើចំណុចនេះថាតើ មានប្រធានបទតូចៗអ្វីខ្លះដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងផ្នែកនេះ។ សហព្រះរាជអាជ្ញាសូមជូនយោបល់ថា ផ្នែកនេះគួរដាក់បញ្ចូលអនុប្រធានបទអំពី*ការបញ្ជូនសំណុំរឿងទៅតុលាការ (saisine)*[4] (ប្រហែល២៥ នាទី) និងយុត្តាធិការលើសំណុំរឿង (សរុបប្រហែល ៣០ នាទី) ដែលរួមមានគោលការណ៍នីត្យានុកូលភាព[5] (ប្រហែល ៣ នាទី) និងច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាតក្នុង*ចេតនាប្រយោល*[6] (ប្រហែល ៦ នាទី) ការធ្វើទុក្ខបុកម្នេញ[7](ប្រហែល ៨ នាទី) និងអំពើអមនុស្សធម៌ផ្សេងៗទៀត[8] (ប្រហែល ១៣ នាទី)។ ប្រសិនបើអនុប្រធានបទណាមួយនៃអនុប្រធានបទទាំងនេះ មិនត្រូវបានបញ្ចូលទៅក្នុងផ្នែកយុត្តាធិការនេះទេ សហព្រះរាជអាជ្ញាសូមស្នើថាពេលវេលាដូចបានជម្រាបជូនខាងលើសម្រាប់អនុប្រធានបទទាំងនោះ ត្រូវបានបែងចែកទៅក្នុងផ្នែកស្តីពីឧក្រិដ្ឋកម្ម។ ពេលវេលាបន្ថែមនេះ គឺជាពេលវេលាបន្ថែមទៅលើពេលវេលាដែលមានរយៈ ២០នាទី ដែលបានស្នើក្នុងកថាខណ្ឌ ៤ សម្រាប់ផ្នែកស្តីពីឧក្រិដ្ឋកម្ម។

### *ឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោស*

៤. សហព្រះរាជអាជ្ញស្នើសុំបន្ថែមពេល ២០នាទី គឺពី៤០ ទៅ ៦០នាទី សម្រាប់សេចក្តីសន្និដ្ឋានរបស់ខ្លួនលើឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោស។ ពេលវេលាបន្ថែមនេះ ត្រូវបានស្នើឡើងដោយហេតុថាផ្នែកនេះទាក់ទងទៅនឹងទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន៨២ ("ទឡ្ហីករណ៍បណ្តឹងសាទុក្ខ")[9] ដែលស្ថិតក្នុងផ្នែកទូលំទូលាយចំនួនប្រាំបីគឺៈ(i) ដល់ (iv) ការកំណត់គោលដៅលើក្រុម

---

[4] *គឺមានន័យថា* ទឡ្ហីករណ៍បណ្តឹងសាទុក្ខ ២-៣, ៣៨-៨៤, ១២៣-១២៤, ១៣៤, ១៨០ សម្រាប់មានចំនួន ៥៣ ទឡ្ហីករណ៍ ដូចបានកំណត់អត្តសញ្ញាណក្នុង F54/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជំទាស់ទៅនឹងសាលក្រមនៃសំណុំរឿង០០២/០២ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ")។

[5] *គឺមានន័យថា* ទឡ្ហីករណ៍បណ្តឹងសាទុក្ខ ៨៥, ដូចបានកំណត់អត្តសញ្ញាណក្នុងឯកសារ F54/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ។

[6] *គឺមានន័យថា* ទឡ្ហីករណ៍បណ្តឹងសាទុក្ខ ៦, ៨៦-៩៣, សរុបមានចំនួន ៩ ទឡ្ហីករណ៍ ដូចបានកំណត់អត្តសញ្ញាណក្នុងឯកសារ F54/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ។

[7] *គឺមានន័យថា* ទឡ្ហីករណ៍បណ្តឹងសាទុក្ខ ៦៨, ៧២, ៧៥-៧៧, ៩៤-៩៦, ១០៧-១០៩, ១១៤, ១២២, ១២៤-១២៦, ១២៩, ១៣៤, ១៤១, ១៤៣-១៤៤, ២៤៦-១៤៩ សរុបមានចំនួន ២៥ ទឡ្ហីករណ៍ ដូចបានកំណត់អត្តសញ្ញាណក្នុងឯកសារ F54/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ។

[8] *គឺមានន័យថា* ទឡ្ហីករណ៍បណ្តឹងសាទុក្ខ ៩៧-៩៨, ១៦០, ១៧១-១៧២ សរុបមានចំនួន ៥ ទឡ្ហីករណ៍ ដូចបានកំណត់អត្តសញ្ញាណក្នុងឯកសារ F54/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ។

[9] *សូមមើល* ឯកសារ F54/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ ផ្នែកទី VII។

ជាក់លាក់ចំនួន៤ គឺពុទ្ធសាសនិកជន មន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរ ជនជាតិចាម និងជនជាតិវៀតណាម (v) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (vi) ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (vii) សហករណ៍និងការដ្ឋាន និង (viii) មន្ទីរសន្តិសុខ។ បន្ថែមលើនេះទៀត សម្រាប់ផ្នែក (i) ដល់ (vi) ទទ្បីករណ៍បណ្តឹងសាទុក្ខចំនួន ៦១ មានរួមបញ្ចូលការជំទាស់សំខាន់ៗរបស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងអត្ថិភាព និងការអនុវត្តគោលនយោបាយទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅលើក្រុមជាក់លាក់ចំនួនបួន និងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ ដែលជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម(“JCE”)[10] ដែលសហព្រះរាជអាជ្ញានឹងត្រូវលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន។

៥. ដូចបានពិភាក្សានៅក្នុងកថាខណ្ឌ ៣ ខាងលើ ប្រសិនបើប្រធានបទស្តីពីយុត្តាធិការ**មិន**រួមបញ្ចូលអនុប្រធានបទណាមួយក្នុងចំណោមអនុប្រធានបទ ដែលសហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍សម្រាប់ផ្នែកនោះ សហព្រះរាជអាជ្ញាស្នើសុំថា ពេលវេលាបន្ថែមដូចបានកំណត់អត្តសញ្ញាណសម្រាប់អនុប្រធានបទនីមួយៗ ត្រូវបន្ថែមទៅក្នុងផ្នែកឧក្រិដ្ឋកម្ម បន្ថែមលើរយៈពេល ២០ នាទីដែលបានស្នើសុំរួចហើយសម្រាប់ប្រធានបទនេះ នៅក្នុងកថាខណ្ឌ ៤។

*ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ*

៦. សហព្រះរាជអាជ្ញាស្នើសុំថា ពេលវេលាសម្រាប់សេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបន្ថែម ២០នាទីទៀត គឺពី៦០នាទី ទៅ៨០នាទី។ ពេលវេលាបន្ថែមនេះត្រូវបានស្នើសុំឡើងដោយហេតុថា ប្រធានបទនេះទាក់ទងទៅនឹងទទ្បីករណ៍បណ្តឹងសាទុក្ខចំនួន៧០[11] ដែលជាចំនួនស្មើនឹងមួយភាគបីនៃសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ[12]។ បន្ថែមលើទទ្បីករណ៍ចំនួន១០ ដែលទាក់ទងនឹងតួនាទី និងមុខងាររបស់ម្ចាស់បណ្តឹងសាទុក្ខ[13] មានទទ្បីករណ៍ចំនួន៥៤ ទាក់ទងផ្ទាល់ទៅនឹងបញ្ហាដ៏ទូលំទូលាយរបស់ JCE ជាពិសេស គោលបំណងរួម

---

[10] *សូមមើល* ឯកសារ **F54/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ ផ្នែកទី VII ដែលលើកឡើងទទ្បីករណ៍បណ្តឹងសាទុក្ខចំនួន ៤៥ ទាក់ទងនឹងការប្រព្រឹត្តលើក្រុមដែលត្រូវបានកំណត់គោលដៅ និងទទ្បីករណ៍បណ្តឹងសាទុក្ខចំនួន ១៦ ទាក់ទងនឹងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍។

[11] *សូមមើល* ឯកសារ **F54/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ ផ្នែកទី VIII។

[12] *សូមមើល*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ផ្នែក IV-V (កថាខណ្ឌ ១៣៩៩-២១៤៣) ដែលមានចំនួន ២៥៣ ទំព័រ នៃសារណាជាភាសាអង់គ្លេសកម្រាស់ ៧៥២ទំព័រ។

[13] *សូមមើល* ឯកសារ **F54/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ ផ្នែកទី VIII(ខ)។

ការចូលរួមចំណែកដ៏សំខាន់របស់ម្ចាស់បណ្ដឹងសាទុក្ខ និងចេតនារបស់គាត់[14]។ ផ្នែកនេះក៏បញ្ចូលទឡ្ហីករណ៍ចំនួន៦ ស្ដីពីការជួយនិងជម្រុញ[15]ផងដែរ នេះជាលើកទីមួយដែលអង្គជំនុំជម្រះនេះត្រូវបានស្នើសុំឱ្យពិចារណាលើទម្រង់នៃការទទួលខុសត្រូវនេះ។

## III. ឧបាស្រ័យដែលស្នើឡើង

៧. សម្រាប់មូលហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើឱ្យ អ.ជ.ត.ក៖

១) បញ្ជាក់ថា តើអនុប្រធានបទ ឬទឡ្ហីករណ៍ណាខ្លះដែលមាននៅក្នុងផ្នែកនៃយុត្តាធិការ។

២) បង្កើនពេលវេលាដែលបានបែងចែកឱ្យសហព្រះរាជអាជ្ញា សម្រាប់ផ្នែកឧក្រិដ្ឋកម្ម ចំនួន ២០ នាទី គឺពី ៤០នាទី ទៅ ៦០នាទី។ ជាងនេះទៀត ប្រសិនបើអនុប្រធានបទណាមួយក្នុងចំណោមអនុប្រធានបទនានាដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា ឬទឡ្ហីករណ៍បណ្ដឹងសាទុក្ខនៅក្នុងកថាខណ្ឌ ៣ (ខាងលើ) ត្រូវបានដកចេញពីផ្នែកយុត្តាធិការ សូមបន្ថែមរយៈពេលដែលបានស្នើសុំសម្រាប់អនុប្រធានបទ ឬទឡ្ហីករណ៍បណ្ដឹងសាទុក្ខទាំងអស់នោះទៅលើរយៈពេល ៦០នាទី ដែលបានស្នើសុំសម្រាប់ផ្នែកឧក្រិដ្ឋកម្មវិញ; ហើយនិង

៣. បង្កើនរយៈពេលដែលមានសម្រាប់សហព្រះរាជអាជ្ញា ក្នុងការធ្វើសេចក្ដីសន្និដ្ឋាន ស្ដីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្ដឹងសាទុក្ខចំនួន២០នាទី គឺពី៦០នាទីទៅ៨០នាទី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | [signature] |

[14] *សូមមើល* ឯកសារ **F54/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខ ផ្នែកទី VIII(គ) ដែលលើកឡើងទឡ្ហីករណ៍បណ្ដឹងសាទុក្ខចំនួន១១ ទាក់ទងនឹងគោលបំណងរួម ទឡ្ហីករណ៍បណ្ដឹងសាទុក្ខចំនួន១២ ទាក់ទងនឹងការចូលរួមចំណែកសំខាន់ៗ និងទឡ្ហីករណ៍បណ្ដឹងសាទុក្ខចំនួន ៣១ ទាក់ទងនឹងចេតនា សរុបមានទឡ្ហីរកណ៍បណ្ដឹងសាទុក្ខចំនួន ៥៤។

[15] *សូមមើល* ឯកសារ **F54/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខ ផ្នែកទី VIII(ឃ)។